**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** ........០២៩......../២៥...............**ក.ប**/ស.ជ.ណ.ម.ហ

# សេចក្តីជូនដំណឹង

## ស្តីពី

## ការស្នើសុំការអនុញ្ញាតប្រើប្រាស់ហត្ថពលកម្មបរទេសសម្រាប់ឆ្នាំ២០២៦

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនដល់ម្ចាស់ ឬនាយកសហគ្រាស ក្រុមហ៊ុន រោងចក្រទាំងអស់ ដែលស្ថិតក្នុងដែនអនុវត្តនៃច្បាប់ស្តីពីការងារឱ្យបានជ្រាបថា ដើម្បីអាចប្រើប្រាស់ហត្ថពលកម្មបរទេសសម្រាប់ឆ្នាំ២០២៦ ម្ចាស់ ឬនាយកសហគ្រាស ក្រុមហ៊ុន រោងចក្រត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតប្រើប្រាស់ហត្ថពលកម្មបរទេស **ចាប់ពីថ្ងៃទី១ ខែកញ្ញា រហូតដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៥** ក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យកម្លាំងពលកម្មបរទេស (Foreign Workers Centralized Management System – FWCMS) តាមរយៈគេហទំព័រ https://fwcms.mlvt.gov.kh/។ ចំពោះសហគ្រាស ក្រុមហ៊ុន រោងចក្រដែលបើកដំណើរការក្រោយកាលបរិច្ឆេទនេះ ហើយមានតម្រូវការប្រើប្រាស់ហត្ថពលកម្មបរទេសអាចស្នើសុំប្រើប្រាស់ហត្ថពលកម្មបរទេសភ្លាមៗ បន្ទាប់ពីសហគ្រាស ក្រុមហ៊ុន រោងចក្រនោះមានដំណើរការ។

ដើម្បីទទួលបានបញ្ជីឈ្មោះកម្មករនិយោជិតខ្មែរ និងបរទេសដោយស្វ័យប្រវត្តិ ម្ចាស់ ឬនាយកសហគ្រាស ក្រុមហ៊ុន រោងចក្រ ត្រូវធ្វើការតភ្ជាប់ប្រព័ន្ធគ្រប់គ្រងទិន្នន័យរួមពាក់ព័ន្ធវិស័យការងារ (Labour Centralized Management System – LACMS) និងប្រព័ន្ធគ្រប់គ្រងទិន្នន័យកម្លាំងពលកម្មបរទេស (Foreign Workers Centralized Management System – FWCMS) ដោយអនុវត្តតាមការណែនាំនៅក្នុងតំណភ្ជាប់នេះ https://lacms.mlvt.gov.kh/backend/guidline/register/how_to_link_FWCMS_LACMS.pdf។

ក្រសួងសូមបញ្ជាក់ថា ជនបរទេសដែលចូលមកស្នាក់នៅនិងប្រកបមុខរបរ ឬធ្វើការនៅព្រះរាជាណាចក្រកម្ពុជា ត្រូវស្នើសុំបណ្ណការងារនិងសៀវភៅការងារជនបរទេសតាមរយៈប្រព័ន្ធFWCMS ក្នុងរយៈពេល ៩០ថ្ងៃយ៉ាងយូរ គិតចាប់ពីកាលបរិច្ឆេទដំបូងដែលបានចូលមកព្រះរាជាណាចក្រកម្ពុជា។

ក្នុងករណីម្ចាស់ ឬនាយកសហគ្រាស ក្រុមហ៊ុន រោងចក្រដែលមានប្រើប្រាស់ហត្ថពលកម្មបរទេសមិនបានស្នើសុំការអនុញ្ញាតប្រើប្រាស់ហត្ថពលកម្មបរទេសសម្រាប់ឆ្នាំ២០២៦ ឬជនបរទេសមិនបានស្នើសុំបណ្ណការងារនិងសៀវភៅការងារជនបរទេសតាមកាលបរិច្ឆេទកំណត់ខាងលើ ត្រូវរងការផាកពិន័យជាប្រាក់ និងចំណាត់ការពីអធិការការងារស្របតាមច្បាប់ជាធរមាន។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សង្ឃឹមយ៉ាងមុតមាំថា ម្ចាស់ ឬនាយកសហគ្រាស ក្រុមហ៊ុន រោងចក្រទាំងអស់អនុវត្តបានត្រឹមត្រូវតាមសេចក្តីជូនដំណឹងនេះប្រកបដោយប្រសិទ្ធភាព។

ថ្ងៃសុក្រ ៦កើត ខែភទ្របទ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២៥

**រដ្ឋមន្ត្រី**

**ហេង សួរ**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- រដ្ឋបាលរាជធានី ខេត្ត
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត
- គ្រប់សមាគមនិយោជក
- ឯកសារ កាលប្បវត្តិ

## របៀបតភ្ជាប់ប្រព័ន្ធ LACMS និង FWCMS របស់
## ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ដើម្បីម្ចាស់ ឬនាយកសហគ្រាស ក្រុមហ៊ុន រោងចក្រ តភ្ជាប់ប្រព័ន្ធគ្រប់គ្រងទិន្នន័យរួមពាក់ព័ន្ធវិស័យការងារ (LACMS) ប្រព័ន្ធគ្រប់គ្រងទិន្នន័យពលករបរទេសរបស់កម្ពុជា (FWCMS) ត្រូវអនុវត្តដូចខាងក្រោម៖

➢ ចូលប្រព័ន្ធ LACMS តាមរយៈគណនីដែលបានបង្កើតរួច ដើម្បីកត់ត្រាលេខ "**LACMS Unique ID**" និងលេខ "**លេខចុះបញ្ជីពាណិជ្ជកម្ម**" នៅ "**ផ្ទាំងព័ត៌មានសហគ្រាស**" តាមគេហទំព័រ www.lacms.mlvt.gov.kh។




➢ ចូលប្រព័ន្ធ FWCMS តាមរយៈគណនីដែលបានបង្កើតរួច ដើម្បីបញ្ចូលលេខ "**LACMS Unique ID**" និងលេខ "**លេខចុះបញ្ជីពាណិជ្ជកម្ម**" នៅ "**ផ្ទាំងមុខងារ**" តាមគេហទំព័រ www.fwcms.mlvt.gov.kh។ បន្ទាប់មកចុច "Save"។




➢ បន្ទាប់ពីប្រព័ន្ធតភ្ជាប់រួច ព័ត៌មានរបស់ សហគ្រាស ក្រុមហ៊ុន រោងចក្រ និងកម្មករនិយោជិតខ្មែរ និងជនបរទេស ដូចគ្នា។